**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៦១២ ប្រក.កសក

# ប្រកាស
## ស្តីពី
## ការបង្កើត និង ការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តកែប

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូ ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ ២១៩ ប្រក.កសក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ



ទីស្នាក់ការលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

## សម្រេច

**ប្រការ ១.-**

បង្កើតតំបន់ព្រៃសហគមន៍ក្នុងខេត្តកែបសម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តភាពតាមលក្ខណៈសហគមន៍ព្រៃឈើ ដែលមានទីតាំងស្ថិតនៅក្នុងផ្នែករដ្ឋបាលព្រៃឈើកែប នៃខណ្ឌរដ្ឋបាលព្រៃឈើកំពត ។

**ប្រការ ២.-**

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលបំណង ៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះ និងអភិវឌ្ឍព្រៃសហគមន៍ឲ្យមាននិរន្តភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅ ទំនៀមទម្លាប់និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាន និងសក្តានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

**ប្រការ ៣.-**

តំបន់ព្រៃសហគមន៍ក្នុងខេត្តកែប នៃប្រកាសនេះមានមួយ (១) សហគមន៍ព្រៃឈើ ដែលមានផ្ទៃដីមួយកន្លែងសរុបចំនួន៥៨៣ (ប្រាំរយប៉ែតសិបបី )ហិកតា ដូចមានក្នុងផែនទីទីតាំងព្រៃសហគមន៍ និងផែនទីព្រៃសហគមន៍នីមួយៗភ្ជាប់ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ និងជាប្រព័ន្ធខ្សែព្រំប៊ិទជិតកំណត់ដោយចំណុចគោល និងនិយាមកាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ ។

**ប្រការ ៤.-**

ដំណើរការរៀបចំ និងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ ។

**ប្រការ ៥.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធនិងប្រធានមន្ទីរកសិកម្មខេត្តកែប ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី...១៥...ខែ...ឧសភា...ឆ្នាំ...២០១១

**រដ្ឋមន្ត្រី**

**ជ័ន្ទ.សារុន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកែប
- ដូចប្រការ ៦

ឯកសារ-កាលប្បវត្តិ

# ផែនទីព្រៃសហគមន៍ ដំណាក់ចង្អើរ សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប

## Damnak Chang Eu Forest Community Prey Thom Commune,Kep District Kep Province



**ឧបសម្ព័ន្ធ** ២ ៈភ្ជាប់ប្រកាសលេខ ...៦១២....ប្រក.កសក.....ចុះថ្ងៃទី ..១៥......ខែ ...៧.........ឆ្នាំ..២០១១........

# ទីតាំងព្រៃសហគមន៍ក្នុងខេត្តកែប

| លរ | ឈ្មោះសហគមន៍ព្រៃឈើ | ផ្ទៃដី (ហិកតា) | ចំណុចនិយាមកា ទីតាំងព្រៃសហគមន៍ | ចំនួនភូមិ | ឈ្មោះឃុំ | ឈ្មោះស្រុក | ផ្នែករដ្ឋបាលព្រៃឈើ |
|---|---|---|---|---|---|---|---|
| ១ | ដំណាក់ចង្អើរ | ៥៨៣ | **A428877-1169090** 428652-1167628 427176-1166307 427601-1168613<br>430605-1168942 428610-1167579 **C426866-1166192** 427758-1168670<br>430583-1168852 428560-1167473 426835-1166394 427869-1168712<br>430547-1168778 428582-1167366 426845-1166664 427985-1168801<br>430487-1168708 428625-1167229 426856-1167286 428188-1168945<br>430376-1168603 428633-1167146 427080-1167316 428449-1169046<br>430215-1168498 428632-1167111 427258-1167396 428626-1169052<br>429883-1168385 428629-1166921 427394-1167419 430615-1169041<br>429791-1168385 427598-1166000 427457-1167465 429175-1169078<br>429749-1168365 427595-1165998 427209-1167589 429429-1169069<br>429698-1168282 427593-1165997 426960-1167542 429706-1169055<br>429690-1168253 427430-1166164 426800-1167647 429904-1169051<br>429673-1168188 429278-1167790 426825-1167788 430096-1169062<br>429644-1168138 429148-1167731 426889-1167882 430341-1169068<br>429604-1168070 **B429000-1167693** **D426951-1167988** 430615-1169041<br>429541-1167994 428885-1167672 427090-1168424 429358-1167831<br>429455-1167907 428785-1167658 | ១ | ព្រៃធំ | កែប | កែប |
| សរុប | | ៥៨៣ | | ១ | ០១ | | ០១ |